00197188

A162/III/2

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
## នៅចំពោះមុខអង្គបុរេជំនុំជម្រះ

សំណុំរឿងលេខ : ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ-០៨)

បញ្ជូនទៅ : អង្គបុរេជំនុំជម្រះ

កាលបរិច្ឆេទនៃឯកសារ : ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨

ភាគីបញ្ជូន : ការិយាល័យសហព្រះរាជអាជ្ញា

ភាសាដើម : អង់គ្លេស

ប្រភេទឯកសារ : សាធារណៈ

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 23/6/2008
ម៉ោង (Time/Heure): 14:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.D.FRY

---

## ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសារណារបស់ អៀង សារី ស្តីពីបញ្ហាទំនាស់ផលប្រយោជន៍ នៃអ្នកស៊ើបអង្កេត ក.ស.ច.ស មួយរូប

---

**បញ្ជូនដោយ៖**

**ការិយាល័យហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Robert PETIT

លោក យ៉េត ចរិយា

លោក William SMITH

លោក តាន់ សេណារ៉ុង

លោក Anees AHMED

**ចែកចាយជូន៖**

**អង្គបុរេជំនុំជម្រះ៖**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម Rowan DOWNING

ចៅក្រម ន័យ ថុល

ចៅក្រម Katinka LAHUIS

ចៅក្រម ហួត វុទ្ធី

**មេធាវីការពារក្តីរបស់ អៀង សារី៖**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certifified Date/Date de certification): 24/06/2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

## ១. សេចក្ដីផ្ដើម

១. សហព្រះរាជអាជ្ញា ស្នើសុំឱ្យ អង្គបុរេជំនុំជម្រះ បដិសេធចោលនូវសារណារបស់ជនត្រូវចោទ អៀង សារី (“សារណា”) ស្ដីពីទំនាស់ផលប្រយោជន៍ជាសក្ដានុពលរបស់អ្នកស៊ើបអង្កេតមួយរូបនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ។ សារណានោះ គឺមិនអាចទទួលយកបានឡើយ ដោយសារហួសពេលវេលា ហើយខុសទម្រង់ ហើយថាទោះជាក្នុងករណីណាក៏ដោយ គឺមិនសមនឹងទទួលយកបានឡើយ[1] ។

## ២. សាវតារអង្គហេតុដែលពាក់ព័ន្ធ

២. នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៨ ជនត្រូវចោទបានដាក់ពាក្យបណ្ដឹងមួយ (“ពាក្យស្នើសុំ”) នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ដើម្បីស្នើសុំព័ត៌មានទាក់ទងទៅនឹង អ្នកស៊ើបអង្កេត/អ្នកស្រាវជ្រាវ/អ្នកវិភាគ មួយរូបនៅក្នុងការិយាល័យរបស់ខ្លួន ។ ពាក្យស្នើសុំនោះបានពោលអះអាងថា អ្នកស៊ើបអង្កេតរូបនេះធ្លាប់បានផ្ដល់ “គំនិត និងសេចក្ដីសន្និដ្ឋាន” នានាដែល “នាំឱ្យមានការចាប់អារម្មណ៍ថាគាត់មានគំនិតវិនិច្ឆ័យទុកជាមុន និងមានភាពលំអៀងជាហេតុធ្វើឱ្យគាត់មិនមានគុណសម្បត្តិគ្រប់គ្រាន់ក្នុងការកាន់មុខតំណែងណាមួយនៅ ក្នុង ក.ស.ច.ស នេះទេ”[2] ។ ដោយសារតែគ្មានសេចក្ដីសម្រេចណាមួយលេចចេញមក ជនត្រូវចោទក៏បាន

---

[1] *ករណីរបស់ អៀង សារី,* បណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់ ក.ស.ច.ស លើសំណើរបស់មេធាវី សុំព័ត៌មានទាក់ទងនឹងភាពលំអៀងដែលឃើញច្បាស់ និង អត្ថិភាពដ៏មានសក្ដានុពលនៃទំនាស់ផលប្រយោជន៍នៃមន្ត្រីផ្នែកច្បាប់របស់ ក.ស.ច.ស ដេវីដ បយល៍ (David Boyle), សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ-០៨), លេខERN 00195028-00195035, A162/III/1, ចុះថ្ងៃទី០៦ មិថុនា ២០០៨ [*បន្ទាប់ពីនេះទៅហៅថា៖* បណ្ដឹងឧទ្ធរណ៍] ។ មន្ត្រីកាន់សំណុំរឿង បានបញ្ជូនបណ្ដឹងឧទ្ធរណ៍នេះជាទម្រង់អេឡិចត្រូនិក ទៅសហព្រះរាជអាជ្ញា នៅថ្ងៃទី០៩ មិថុនា ២០០៨ នៅវេលាម៉ោង ១២ និង ១២ នាទី ថ្ងៃត្រង់ ។

[2] *ករណីរបស់ អៀង សារី,* សំណើរបស់មេធាវីសុំព័ត៌មានទាក់ទងនឹងភាពលំអៀងដែលឃើញច្បាស់ និង អត្ថិភាពដ៏មានសក្ដានុពលនៃទំនាស់ផលប្រយោជន៍នៃមន្ត្រីផ្នែកច្បាប់របស់ ក.ស.ច.ស ដេវីដ បយល៍ (David Boyle), សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/

រំលឹកដល់សហចៅក្រមស៊ើបអង្កេត តាមរយៈលិខិតមួយចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៨ ស្ដីពី "សំនួរ(interrogatories)" ទាំងឡាយរបស់ខ្លួន ហើយបានស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតផ្ដល់នូវសេចក្ដីសម្រេចមួយដល់ខ្លួនឱ្យបានឆាប់រហ័ស[3] ។ នៅថ្ងៃ ទី២៦ ខែឧសភា ឆ្នាំ ២០០៨ សហចៅក្រមស៊ើបអង្កេតបានឆ្លើយតបតាមរយៈលិខិតមួយ ("លិខិតស្នូរដេញដោល") ដែលបានសរសេរថា៖

i. ការដាក់ពាក្យនេះ គឺស្រដៀងគ្នាទៅនឹងសំណើមិនបានជោគជ័យមួយ ដែលដាក់ដោយជនត្រូវចោទ ពាក់ព័ន្ធនឹងអ្នកស៊ើបអង្កេតមួយរូបផ្សេងទៀត[4] ។ សហចៅក្រមស៊ើបអង្កេត បានរំលឹកឡើងវិញនៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៨ នៅពេលដែលច្រានចោលសំណើមួយដែល "ពាក់ព័ន្ធទៅនឹងទំនាស់ផលប្រយោជន៍ជាសក្ដានុពល" របស់អ្នកស៊ើបអង្កេតមួយរូបផ្សេងទៀត សហចៅក្រមស៊ើបអង្កេតបានសម្រេចសេចក្ដីថា អ្នកស៊ើបអង្កេតទាំងឡាយនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត គឺមានលក្ខណៈដូចគ្នានឹងមន្ត្រីនគរបាលយុត្តិធម៌ ដោយបំពេញតួនាទីរបស់ខ្លួននៅក្រោមការគ្រប់គ្រងរបស់ចៅក្រមមានសមត្ថកិច្ច ឬព្រះរាជអាជ្ញាមានសមត្ថកិច្ច ។ សហចៅក្រមស៊ើបអង្កេត បានបន្ថែមថាវិធានដែលធានាពីឯករាជ្យភាព និងភាពមិនលំអៀងរបស់តុលាការនោះអនុវត្តសំដៅ "តែទៅលើចៅក្រមប៉ុណ្ណោះ និងមិនអនុវត្តចំពោះអ្នកស៊ើបអង្កេតទេ"[5] ។

---

អ.វ.ត.ក/ក.ស.ច.ស, លេខERN 00165542-00165547, A162, ចុះថ្ងៃទី០៤ មីនា ២០០៨, កថាខណ្ឌទី ២ [*បន្ទាប់ពីនេះទៅហៅថា៖* ពាក្យស្នើសុំ] ។

[3] *ករណីរបស់ អៀង សារី,* សម្ដីពាក់ព័ន្ធនឹងការសួរចម្លើយលោក អៀង សារី អំពីស្ថានភាពនៃការឃុំខ្លួនរបស់គាត់ នៅថ្ងៃទី០២ ឧសភា ២០០៨, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក/ក.ស.ច.ស, លេខERN 00185454-00185456, C31, ចុះថ្ងៃទី២៤ មេសា ២០០៨, ទំព័រទី ៣ [*បន្ទាប់ពីនេះទៅហៅថា៖* លិខិតរំលឹក] ។

[4] *ករណីរបស់ អៀង សារី,* សំណើសុំផ្ដល់ព័ត៌មានទាក់ទិននឹងករណីទំនាស់ផលប្រយោជន៍ជាយថាហេតុ, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក/ក.ស.ច.ស, លេខERN 00159515-00159516, A121/1, ចុះថ្ងៃទី២៤ មករា ២០០៨ [*បន្ទាប់ពីនេះទៅហៅថា៖* សេចក្ដីសម្រេចលើករណីលោក Heder] ។

[5] សេចក្ដីសម្រេចលើករណីលោក Heder, ទំព័រទី ២ ។

ii. វិធានផ្ទៃក្នុង មិនបានចែងអំពីបណ្ដឹងជិតចិត្តចំពោះអ្នកស៊ើបអង្កេតទេ ។

iii. មាននីតិវិធីជាក់លាក់មួយតាមវិធាន ៣៤ នៃវិធានផ្ទៃក្នុង សម្រាប់បណ្ដឹងជិតចិត្តចំពោះចៅក្រម (“វិធាន”) ។ ភាគីដែលធ្វើបណ្ដឹងជិតចិត្ត (ហើយគឺមិនមែនអ្នកស៊ើបអង្កេតទេ) ត្រូវបង្ហាញភស្តុតាងក្នុងការគាំទ្របណ្ដឹងបែបដូច្នេះ[6] ។

៣. ដោយមានការអាក់អន់ចិត្តទៅនឹងលិខិតស្នួរដេញដោលនោះ ជនត្រូវចោទបានដាក់សារណាបច្ចុប្បន្ននេះ ។

## ៣. អំពីសំណើជំហូទ

### *មិនចាំបាច់តម្រូវឱ្យមានសវនាការផ្ទាល់មាត់ទេ*

៤. សហព្រះរាជអាជ្ញា សន្និដ្ឋានថា នេះគឺមិនមែនជាករណីមួយសមស្រប ដើម្បីត្រូវកំណត់អំពីញត្តិជាលាយលក្ខអក្សរតែឯកឯង ដោយមិនមានដំណោះស្រាយមួយជាសវនាការផ្ទាល់មាត់នោះទេ ។ សហព្រះរាជអាជ្ញា ស្នើថា អង្គបុរេជំនុំជម្រះមិនគប្បីបកស្រាយពាក្យ “សវនាការ” នៅក្នុងវិធាន ៧៧ ត្រឹមតែមានន័យថាជាសវនាការ *ផ្ទាល់មាត់* នោះទេ ក៏ប៉ុន្តែគប្បីបកស្រាយពាក្យនោះ ដោយបញ្ចូលនូវការកំណត់មួយដោយមានមូលដ្ឋាននៅលើញត្តិនានាជាលាយលក្ខអក្សរផងដែរ ។ សេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ គាំទ្រនូវសេចក្ដីអះអាងនេះក្នុងន័យដែលថា សេចក្ដីណែនាំអនុវត្តនោះ បានប្រមើលមើលឃើញនូវស្ថានភាពនានាដែល *“មិនមានការបង្ហាញសំអាងផ្ទាល់មាត់”* [7] ។ នេះក៏គឺជាការអនុវត្តន៍នៅចំពោះមុខតុលាការ

---

[6] *ករណីរបស់ អៀង សារី,* សំណើសុំព័ត៌មានទាក់ទិននឹង “ភាពលំអៀងដែលអាចមើលឃើញ និងទំនាស់ផលប្រយោជន៍ដែលអាចកើតមានឡើង ពាក់ព័ន្ធនឹងលោក S. Heder និង D. Boyle”, សំណុំរឿងលេខ ០០២/១៩- ០៩-២០០៧/អ.វ.ត.ក/ក.ស.ច.ស, លេខERN 00193591, A162/2, ចុះថ្ងៃទី២៦ ឧសភា ២០០៨ [*បន្ទាប់ពីនេះទៅហៅថា៖* លិខិតស្នួរដេញដោល] ។

[7] ការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក, សេចក្ដីណែនាំអនុវត្ត 01/2007/Rev.1, ចុះថ្ងៃទី០៥ តុលា ២០០៨, មាត្រា ៨.៤ (សេចក្ដីសង្កត់ន័យបន្ថែមជា *អក្សរទ្រេត*) ។

ព្រហ្មទណ្ឌអន្តរជាតិនានាដែលស្រដៀងគ្នាផងដែរ[8] ។ ការអនុវត្តន៍នេះ គាំទ្រដល់ចរិកា របស់តុលាការ និងការពារបាននូវសិទ្ធិនានារបស់ភាគីទាំងអស់ ។

*ព័ត៌មានសាធារណៈ*

៥. វិធាន ៧៧.៦ ចែងថា អង្គបុរេជំនុំជម្រះ អាចសម្រេចថា នីតិវិធីទាំងស្រុង ឬ មួយផ្នែកនៃ សវនាការ (ហើយបើតាមការពិចារណា គឺសេចក្តីសម្រេចនានា) ត្រូវធ្វើឡើងជាសាធារណៈ បើអង្គបុរេជំនុំជម្រះយល់ឃើញថា ដើម្បីជាប្រយោជន៍យុត្តិធម៌ និងមិនធ្វើឲ្យប៉ះពាល់ដល់ សណ្តាប់ធ្នាប់សាធារណៈ ឬ វិធានការការពាររបស់តុលាការ[9] ។ ការអនុវត្តន៍របស់ អង្គបុរេជំនុំជម្រះ បានឆ្លុះបញ្ចាំងពីស្មារតីនៃវិធាននេះ ក្នុងន័យដែលថាអង្គបុរេជំនុំជម្រះបាន បើកសវនាការរបស់ខ្លួនជាសាធារណៈ ដោយបានស្វែងរកជំនួយពីបណ្តាមិត្តរបស់តុលាការ *(amici curiae)* បានចេញសេចក្តីសម្រេចជាសាធារណៈ ព្រមទាំងបានដាក់សេចក្តីសម្រេច នានារបស់ខ្លួន និងសារណាផ្សេងៗរបស់ភាគីនានាចូលទៅក្នុងវិបសាយរបស់អង្គជំនុំជម្រះ ទៀតផង ដើម្បីជាផលប្រយោជន៍នៃការចែកចាយព័ត៌មានឲ្យបានទូលំទូលាយ និងជាយាន មួយរបស់អង្គជំនុំជម្រះនេះ ដើម្បីធ្វើការផ្សព្វផ្សាយព័ត៌មានដល់សហគមន៍ ។

៦. ដោយចង់ឲ្យមានភាពរលូនជាមួយនឹងការអនុវត្តន៍នេះ សហព្រះរាជអាជ្ញា ស្នើសុំឲ្យ អង្គបុរេជំនុំជម្រះ ដាក់ចម្លើយតបនេះចូលទៅក្នុងវិបសាយរបស់អង្គជំនុំជម្រះ ទន្ទឹមគ្នានឹង ការដាក់ឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងសារណាបែបមួយនេះ ហើយដែលអង្គបុរេជំនុំជម្រះ យល់ឃើញថាសមស្របទៅនឹងផលប្រយោជន៍យុត្តិធម៌ ។

## ៣. ច្បាប់ស្តីពីទំនាស់ផលប្រយោជន៍
### *ឯករាជ្យភាព និង ភាពមិនលំអៀងរបស់ចៅក្រម*

[8] *រដ្ឋអាជ្ញា ទល់នឹង Krnojelac,* សេចក្តីសម្រេចលើញត្តិដំបូងរបស់មេធាវីការពារក្តី ស្តីពីទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ, សំណុំរឿងលេខ IT-97-25-T, អង្គជំនុំជម្រះសាលាដំបូងទី II នៃតុលាការ ICTY, ចុះថ្ងៃទី២៤ កុម្ភៈ ១៩៩៩ កថាខណ្ឌទី ៦៥-៦៨ ។

[9] វិធានផ្ទៃក្នុង, វិធាន ៧៧.៦ ។

៧. មាត្រា ១២៨ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា ចែងអំពីប្រព័ន្ធតុលាការមួយដែលឯករាជ្យ និងមិនលំអៀង ។ គតិច្បាប់ជាមូលដ្ឋាននេះ កំពុងឆ្លុះបញ្ចាំងនៅក្នុងកិច្ចព្រមព្រៀង និងក្នុងច្បាប់ អ.វ.ត.ក ដែលចែងថា គ្រប់ចៅក្រមជម្រះក្តីទាំងអស់នៃ អ.វ.ត.ក ត្រូវឯករាជ្យក្នុងការបំពេញការងាររបស់ខ្លួន ហើយមិនត្រូវទទួល ឬស្វែងរកការបង្គាប់ បញ្ជាពីប្រភពណាមួយឡើយ[10] ។ ការធានាជាសារវ័ន្តដូចគ្នានេះមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (“ICCPR”)[11] អនុសញ្ញាស្តីពីសិទ្ធិមនុស្សសម្រាប់ទ្វីបអឺរ៉ុប (“ECHR”)[12] អនុសញ្ញាស្តីពីសិទ្ធិមនុស្សសម្រាប់អន្តរទ្វីបអាមេរិក (“IACHR”)[13] ហើយនិងធម្មនុញ្ញស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាពលរដ្ឋសម្រាប់ទ្វីបអាហ្វ្រិក (“ACHPR”)[14] ។ ជាការពិត គណៈកម្មាធិការសិទ្ធិមនុស្សរបស់ អ.ស.ប បានថ្លែងថាការធានានូវឯករាជ្យភាព និងភាពមិនលំអៀង “គឺជាសិទ្ធិដាច់ខាត ដែលអាចនឹងរងគ្រោះដោយគ្មានការលើកលែងឡើយ”[15] ។

៨. គេយល់ថា ឯករាជ្យភាព និងភាពមិនលំអៀង នៃតុលាការនិងអង្គជំនុំជម្រះអន្តរជាតិ គឺជាធាតុផ្សំដ៏សំខាន់ នៅក្នុងដំណើរស្វែងរករបស់ពួកខ្លួននូវភាពទទួលស្គាល់តាមផ្លូវច្បាប់ក្នុងក្រសែភ្នែករបស់ភាគីនានា គូក្តីសក្តានុពលផ្សេងៗ ព្រមទាំងសហគមន៍អន្តរជាតិជាទូទៅ[16] ។ សញ្ញាណ នៃឯករាជ្យភាព និងភាពមិនលំអៀង គឺជាការណ៍មួយដែលខានមិនបានចំពោះការចាប់អារម្មណ៍យូរអង្វែងនៃការវិនិច្ឆ័យជាអន្តរជាតិ ហើយភាពដែលគួរឲ្យជឿជាក់បាននៃឯករាជ្យភាព និងភាពមិនលំអៀង គឺជាជម្រើសមួយដែលគ្មានលក្ខណៈនយោបាយ សម្រាប់

---

[10] កិច្ចព្រមព្រៀង, មាត្រា ៣.៣ ។ ច្បាប់ អ.វ.ត.ក, មាត្រា ១០ (ថ្មី) ។

[11] ICCPR, មាត្រា ១៤.១ ។

[12] ECHR, មាត្រា ៦.១ ។

[13] IACHR, មាត្រា ៨.១ ។

[14] ACHPR, មាត្រា ៧.១ ។

[15] *ករណីរបស់ Gonzalez del Rio ទល់នឹង ប្រទេសប៉េរូ,* លិខិតប្រាស្រ័យទាក់ទងលេខ ២៦៣/១៩៨៧, ឯកសាររបស់ អ.ស.ប CCPR/C/46/D/263/1987, ចុះថ្ងៃទី២៨ តុលា ១៩៩២ ។

[16] *Yuval Shany & Sigall Horovitz,* ឯករាជ្យភាពរបស់តុលាការនៅទីក្រុង ឡាអេ និង ហ្វ្រីថោន, ទស្សនាវដ្តីច្បាប់អន្តរជាតិ Leiden, ច្បាប់ចេញផ្សាយលេខ ២១ (ឆ្នាំ២០០៨), ទំព័រទី ១២០ ។

ជំនួសឲ្យការដោះស្រាយជម្លោះតាមបែបនយោបាយ[17] ។ មូលដ្ឋានដោយគ្រាន់តែមានការព្រមព្រៀងគ្នានៃដំណើរការវិនិច្ឆ័យជាអន្តរជាតិជាច្រើន ភាពទន់ខ្សោយនៃការអនុវត្តន៍ដំណើរការនីតិវិធី ។ល។ បានផ្តល់នូវការគាំទ្របន្ថែមទៀតសម្រាប់ធ្វើការដោះស្រាយឆ្ពោះទៅរកបទដ្ឋានយ៉ាងហ្មត់ចត់នៃឯករាជ្យភាព និងភាពមិនលំអៀង ក្នុងគោលបំណងដើម្បីកសាងនូវទំនុកចិត្តទៅខាងមុខទៀតនៅក្នុងកិច្ចការនៃប្រព័ន្ធយុត្តិធម៌អន្តរជាតិ និងដើម្បីសម្រួលដល់ការអនុវត្តន៍តាមសេចក្តីសម្រេចរបស់ខ្លួនដោយស្ម័គ្រចិត្ត[18] ។ បន្ថែមលើនេះ តុលាការចម្រុះ ឬតុលាការកូនកាត់ ដូចជាអង្គជំនុំជម្រះនេះជាដើម ត្រូវទទួលបន្ទុកបន្ថែមទៀតក្នុងការអនុវត្តន៍តាមឧទាហរណ៍ជាគំរូមួយចំនួន នៅតាមតុលាការក្នុងស្រុកជាក់លាក់មួយចំនួន ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍[19] ។

៩. ការសន្មតជាមុនអំពីភាពមិនលំអៀង គឺភ្ជាប់ទៅនឹងចៅក្រម[20] ។ ការសន្មតនេះមានមូលដ្ឋានចេញមកពីពាក្យសម្បថចូលកាន់តំណែងរបស់ពួកគេ និងមកពីគុណសម្បត្តិក្នុងការជ្រើសរើសដើម្បីធ្វើការចាត់តាំង ។ ការសន្មតនេះ អនុវត្តចំពោះចៅក្រមទាំងឡាយនៃអង្គជំនុំជម្រះនេះតាមស្មារតីមាត្រា ៣.៣ នៃកិច្ចព្រមព្រៀង[21] ។ ការសន្មតនេះ បានដាក់បន្ទុកយ៉ាងធ្ងន់ទៅលើអ្នកដាក់ពាក្យ ដើម្បីឲ្យរកអ្វីមកជំនួសការសន្មតនេះ[22] និងដាក់ជូននូវភស្តុតាងឲ្យបានគ្រប់គ្រាន់ ដើម្បីបង្ហាញថា ចៅក្រមរូបនេះត្រូវបានគេមើលឃើញជាសត្យានុម័ត ថាមាន

---

[17] *Shany & Horovitz,* ទំព័រទី ១២០ ។

[18] *Shany & Horovitz,* ទំព័រទី ១២០ ។

[19] *Shany & Horovitz,* ទំព័រទី ១២០ ។

[20] *ករណីរបស់ នួន ជា,* សេចក្តីសម្រេចជាសាធារណៈស្តីពីបណ្តឹងជំទាស់ចំពោះចៅក្រមជាបន្ទាន់ របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោក ចៅក្រម ន័យ ថុល ក្នុងការពន្យារបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នទៅក្នុងករណី នួន ជា ។ សំណុំរឿងលេខ ០០២/១៩-០៩- ២០០៧/អ.វ.ត.ក/ក.ស.ច.ស (អបជ-០១), លេខERN 00160734-00160742, C11/29, ចុះថ្ងៃទី០៤ កុម្ភៈ ២០០៨ កថាខណ្ឌទី ១៥ [*បន្ទាប់ពីនេះទៅហៅថា៖* សេចក្តីសម្រេចរបស់ចៅក្រម ន័យ ថុល] ។

[21] សេចក្តីសម្រេចរបស់ចៅក្រម ន័យ ថុល, កថាខណ្ឌទី ១៦ ។

[22] សេចក្តីសម្រេចរបស់ចៅក្រម ន័យ ថុល, កថាខណ្ឌទី ១៥ ។

លក្ខណៈលំអៀង[23] ។ ផ្ទុយទៅវិញ បើមិនមានភស្តុតាងទេ គេត្រូវតែសន្មតថាចៅក្រមទាំងនោះ“អាចកែសេចក្តីយល់ខុសលើបញ្ហាជំនឿ ឬការជំរុញចិត្តផ្ទាល់ខ្លួនរបស់ពួកគេ បាន”[24] ។

១០. ការបញ្ចេញទស្សនៈយល់ឃើញ ឬទំនោរចិត្តរបស់ចៅក្រមណាម្នាក់ដែលមានលក្ខណៈជាទូទៅគួរតែញែកឲ្យដាច់ពីគ្នាពីទំនោរចិត្តក្នុងការអនុវត្តទៅតាមទស្សនៈយល់ឃើញទាំងនោះក្នុងនាមជាចៅក្រមនៅករណីរឿងក្តីណាមួយ[25]។ ចៅក្រមទាំងឡាយ គឺសុទ្ធតែមានជំនឿផ្ទាល់របស់ខ្លួនម្នាក់ៗ[26]។ ភាពជាអព្យាក្រិត្យដាច់ខាតគឺជាការលំបាកណាស់មិនងាយនឹងធ្វើឲ្យបានសម្រេចនោះទេ[27]។ ទោះបីជាថាមានចិត្តអាណិតអាសូរខាងនយោបាយនោះក្តី នោះក៏មិនបានន័យថា ជាគ្មានភាពលំអៀងនោះដែរ[28]។ មិនត្រូវដកចៅក្រមចេញដោយសារតែលក្ខណៈសម្បត្តិដែលគាត់មាននោះទេ ដែលគឺលក្ខណៈសម្បត្តិនេះតែម្តងដែលដើរតួទាំងស្រុងនៅក្នុងការបំពេញគ្រប់គ្រាន់សេចក្តីតម្រូវតាមសិទ្ធិដែលត្រូវបានទទួល[29]។ នេះគឺមុខជា “ជាលទ្ធផលដ៏ចម្លែកពីគេមួយ” សិនជាដំណើរការការងារនៃសេចក្តីតម្រូវទៅតាមសិទ្ធិដែលត្រូវបានទទួលណាមួយនឹងបណ្តាលឲ្យការជ្រៀតជ្រែកដោយភាពលំអៀង[30]។ ការដែលធ្លាប់មានបទពិសោធន៍ក្នុងវិស័យដែលពាក់ព័ន្ធណាមួយដោយចៅក្រមណាមួយរូប បើមិនមានភស្តុតាងផ្ទុយដ៏ច្បាស់លាស់បំផុតទេនោះ គឺមិនអាចបង្កើតបានជាភស្តុតាងដែលបង្ហាញឲ្យឃើញថា មានភាពលំអៀង ឬ អគតិបានដែរ[31]។

---

[23] សេចក្តីសម្រេចរបស់ចៅក្រម ន័យ ផុល, កថាខណ្ឌទី ១៩ ។ រដ្ឋអាជ្ញា ទល់នឹង Furundzija, សាលដីកា, សំណុំរឿងលេខ IT-95.17/1-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY, ចុះថ្ងៃទី២១ កក្កដា ២០០០ កថាខណ្ឌទី ១៩៦ [*បន្ទាប់ពីនេះទៅហៅថា៖* សាលដីកាសម្រេចលើករណីរបស់ Furundzija] ។

[24] សាលដីកាសម្រេចលើករណីរបស់ Furundzija, កថាខណ្ឌទី ១៩៦ ។

[25] សាលដីកាសម្រេចលើករណីរបស់ Furundzija, កថាខណ្ឌទី ២០០ ។

[26] សាលដីកាសម្រេចលើករណីរបស់ Furundzija, កថាខណ្ឌទី ២០៣ ។

[27] សាលដីកាសម្រេចលើករណីរបស់ Furundzija, កថាខណ្ឌទី ២០៣ ។

[28] សាលដីកាសម្រេចលើករណីរបស់ Furundzija, កថាខណ្ឌទី ២០៣ ។

[29] សាលដីកាសម្រេចលើករណីរបស់ Furundzija, កថាខណ្ឌទី ២០៥ ។

[30] សាលដីកាសម្រេចលើករណីរបស់ Furundzija, កថាខណ្ឌទី ២០៥ ។

[31] សាលដីកាសម្រេចលើករណីរបស់ Furundzija, កថាខណ្ឌទី ២០៥ ។

១១. វិធាន៣៤.២ ចែងអំពីយន្តការដើម្បីដកចៅក្រមរបស់ អ.វ.ត.ក ចេញ ទាំងខ្លឹមសារនិងទាំងស្មារតី គឺវាមិនមានការខុសគ្នាពីវិធានទាំងឡាយជាធរមានដែលស្រដៀងគ្នានៅតាមតុលាការពិសេសអន្តរជាតិនានា ដូចជាតុលាការសម្រាប់អតីតប្រទេសយូហ្គោស្លាវី("ICTY")[32] សម្រាប់ប្រទេសរវ៉ាន់ដា("ICTR")[33] និងសម្រាប់ប្រទេសសៀរ៉ាឡេអូន("SCSL")[34] និងតុលាការព្រហ្មទណ្ឌអន្តរជាតិអចិន្ត្រៃយ៍ ("ICC")[35] និងតុលាការយុត្តិធម៌អន្តរជាតិ ("ICJ")[36] នោះទេ ។

១២. តុលាការនេះដែលជាតុលាការអន្តរជាតិ អនុវត្តនូវនិយាមនិងបទដ្ឋានអន្តរជាតិ[37]។ យុត្តិសាស្ត្រដែលបានព្រមព្រៀងគ្នានៃសាលាក្តីអន្តរជាតិ គឺមានភាពស៊ីគ្នាសង្វាក់គ្នាជាមួយនឹងការធ្វើតេស្តសាកល្បងអំពីភាពលំអៀង ដែលបានអនុវត្តនៅចំពោះមុខតុលាការនេះ[38] ។ នៅក្នុងករណី *Furundzija,* ICTY បានសំរេចថា ចៅក្រមមិនត្រឹមតែត្រូវវៀរចាកពីភាពលំអៀងជាអត្តនោម័តប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមិនត្រូវឲ្យពាក់ព័ន្ធនឹងអ្វីៗទាំងអស់ដែលមាននៅក្នុងកាលៈទេសៈជុំវិញដែលផ្តល់ជាសត្យានុម័ត នូវកំណើនទៅក្នុងការបង្ហាញឲ្យឃើញពីភាពលំអៀង។ ហេតុដូច្នេះ ចៅក្រមម្នាក់អាចនឹងត្រូវបានគេគិតថា ខ្វះឯករាជ្យភាព និងភាពមិនលំអៀង (ហើយដែលជាកម្មវត្ថុនៃការប្តឹងជំទាស់) ថាតើ "ភាពលំអៀងជាក់ស្តែងកើតមាន" ("តេស្តសាកល្បងអត្តនោម័ត") ឬ ក៏មាន "ការបង្ហាញនៃភាពលំអៀងដែលមិនអាចទទួលយកបាន ("តេស្តសាកល្បងសត្យានុម័ត")[39] ។

---

32 វិធាននៃនីតិវិធី និងភស្តុតាងសម្រាប់តុលាការ ICTY, វិធាន ១៥.ក ។
33 វិធាននៃនីតិវិធី និងភស្តុតាងសម្រាប់តុលាការ ICTR, វិធាន ១៥.ក ។
34 វិធាននៃនីតិវិធី និងភស្តុតាងសម្រាប់តុលាការ SCSL, វិធាន ១៥.ក ។
35 វិធាននៃនីតិវិធី និងភស្តុតាងសម្រាប់តុលាការ ICC, វិធាន ៣៤.១ ។
36 លក្ខន្តិកៈសម្រាប់តុលាការ ICJ, មាត្រា ១៧.២ ។
37 សេចក្តីសម្រេចរបស់ចៅក្រម ន័យ ធុល, កថាខណ្ឌទី ៣០ ។
38 សេចក្តីសម្រេចរបស់ចៅក្រម ន័យ ធុល, កថាខណ្ឌទី ២០ ។
39 សាលដីកាសម្រេចលើករណីរបស់ Furundzija, កថាខណ្ឌទី ១៨៩-១៩០ ។

១៣. ដោយការដកស្រង់ករណី *Furundzija* ដោយមានការយល់ព្រម អង្គបុរេជំនុំជម្រះនៃតុលាការនេះ បានសំរេចថា មានការបង្ហាញនូវភាពមិនលំអៀង ប្រសិនបើ៖

i. ចៅក្រមណាម្នាក់គឺជាភាគីម្ខាងទៅនឹងរឿងក្តី ឬមានផលប្រយោជន៍ខាងហិរញ្ញវត្ថុ ឬកម្មសិទ្ធិនៅក្នុងលទ្ធផលនៃរឿងក្តីណាមួយ ឬបើសិនសេចក្តីសម្រេចនឹងនាំដល់ការលើកកំពស់នៃបុព្វហេតុណាមួយ ដែលខ្លួនបានចូលរួមពាក់ព័ន្ធជាមួយនឹងភាគីមួយក្នុងចំណោមគូភាគី ។ នៅក្រោមកាលៈទេសៈទាំងអស់នេះ ការដិតចិត្តរបស់ចៅក្រមណាម្នាក់ពីករណីរឿងណាមួយ គឺត្រូវកើតឡើងដោយស្វ័យប្រវត្តិ ;

ii. កាលៈទេសៈទាំងឡាយណាដែលនឹងនាំឲ្យអ្នកសង្កេតការណ៍ម្នាក់ ដែលបានដឹងយ៉ាងត្រឹមត្រូវ ឈានដល់ការលំអៀងណាមួយអាចឲ្យគេយល់បានយ៉ាងសមស្រប[40] ។

១៤. បុគ្គលអ្នកសង្កេតដែលមានហេតុផល នៅក្នុងបរិបទនេះ គឺជាបុគ្គលដែលដឹង និងមានចំណេះដឹងអំពីកាលៈទេសៈពាក់ព័ន្ធទាំងអស់ រួមទាំងប្រពៃណីនៃសុច្ចរិតភាព និងភាពមិនលំអៀងដែលបង្កើតបានជាទម្រង់នៃផ្នែកណាមួយនៃសាវតា ហើយដែលបានវាយតម្លៃទៅលើការពិតដែលថា ភាពមិនលំអៀងនោះ គឺជាភារៈកិច្ចមួយក្នុងចំណោមភារៈកិច្ចនានាដែលចៅក្រមស្បថដើម្បីលើកស្ទួយ[41] ។

១៥. ជាពិសេស នៅក្នុងករណីរបស់ *Furundzija,* ICTY បានបដិសេធសំណើមួយដែលស្នើធ្វើបណ្តឹងដិតចិត្តចៅក្រម Mumba ដោយលើកទឡ្ហីករណ៍ថា លោកស្រីចៅក្រមរូបនេះបានធ្វើការសម្រេចចិត្តចំពោះសាលក្រមនៅក្នុងករណីមួយដែលអាចពន្លឿនដល់(ការពិតវាបានពន្លឿនមែន) នៅក្នុងរបៀបវារៈច្បាប់ និងនយោបាយដែលគាត់បានជួយបង្កើតឡើង ក្នុងពេលដែលគាត់នៅជាសមាជិកម្នាក់របស់គណៈកម្មការអង្គការសហប្រជាជាតិមួយនៅឡើយ មុនពេល

---

[40] សេចក្តីសម្រេចរបស់ចៅក្រម ន័យ ចុល, កថាខណ្ឌទី ២១ ។

[41] សេចក្តីសម្រេចរបស់ចៅក្រម ន័យ ចុល, កថាខណ្ឌទី ២០ ។

ចូលរួមសាលាក្តីនោះ[42] ។ នៅក្នុងករណី *Akayesu,* ICTY បានបដិសេធចំពោះការទាមទារដែលថា សម្តាធខាងនយោបាយបានបំផ្លាញនូវឯករាជ្យភាព និងភាពមិនលំអៀងរបស់សាលាក្តីនោះ ។ ចុងចោទបានតវ៉ាថា ចំណាប់អារម្មណ៍ធ្វើឡើងដោយចៅក្រម "ជាសាធារណៈ និងជាឯកជន" រួមជាមួយ "សម្តាធ និង ការចាត់ចែងជាពិសេសនានា" ហាក់បានបង្ហាញឱ្យឃើញពីភាពលំអៀងប្រឆាំងនឹងរូបគាត់ ។ សាលាក្តីនេះបានកត់សំគាល់ឃើញថា ចុងចោទមានបន្ទុកក្នុងការបង្កើតនូវកង្វះខាតរបស់ខ្លួនចំពោះភាពមិនលំអៀង ឬឯករាជ្យភាព តាមរយៈ "ភស្តុតាងគ្រប់គ្រាន់និងអាចជឿទុកចិត្តបាន" និងថាគាត់មិនអាចបំពេញបាននូវបន្ទុកនេះឡើយ បើសិនជាមានតែការចោទប្រកាន់ទទេស្អាតនៃការផ្តន្ទាទោសដែលលំអៀង និងចោះៗនោះ[43] ។ ស្រដៀងគ្នានេះដែរ ICJ ក៏បានបដិសេធចំពោះសំណើមួយដោយប្រទេសអ៊ីស្រាអែល ដើម្បីឱ្យដកចៅក្រម Elaraby ចេញពីការជំនុំជម្រះក្តីនៅក្នុង *ករណី Wall Case* ដោយយកការចូលរួមពាក់ព័ន្ធមុនៗរបស់ចៅក្រមរូបនេះ ធ្វើជាមូលហេតុនៅក្នុងជម្លោះរវាង ប៉ាលីស្ទីននិងអ៊ីស្រាអែល ក្នុងនាមគាត់អ្នកការទូតអេជីព និងការបញ្ចេញទស្សនៈនានាដោយរូបគាត់ផ្ទាល់នៅក្នុង បទសម្ភាសន៍មួយ ។ តុលាការបានសម្រេចថា ចំពោះអង្គហេតុទាំងអស់នោះមិនអាចដាក់ទៅលើចៅក្រមថា "បានចូលរួមនៅក្នុងករណីលើកមុន" តាមសមត្ថភាពណាមួយនោះឡើយ[44] ។ ប៉ុន្តែ SCSL បានបណ្តេញចៅក្រម Robertson ចេញពីសវនាការនៃករណីមួយដោយសារការបញ្ចេញទស្សនៈទាំងឡាយ ដែលមាននៅក្នុងសៀវភៅមួយ ដែលបានបោះពុម្ពផ្សាយទាក់ទិននឹងបទឧក្រិដ្ឋនានា ដែលបានប្រព្រឹត្តឡើងដោយភាគីម្ខាងទៀតនៃករណីនោះ[45]។

## *ឯករាជ្យភាព និងភាពមិនលំអៀងនៃមន្ត្រីតុលាការក្រៅពីចៅក្រម*

---

[42] សាលដីកាសម្រេចលើករណីរបស់ Furundzija, កថាខណ្ឌទី ២១៥ ។

[43] *រដ្ឋអាជ្ញា ទល់នឹង Akayesu,* សាលដីកានៃអង្គជំនុំជម្រះសាលាឧទ្ធរណ៍, សំណុំរឿងលេខ ICTY-96-4, ចុះថ្ងៃទី០១ មិថុនា ២០០១ កថាខណ្ឌទី ៩០ ។

[44] *ផលវិបាកផ្នែកច្បាប់នៃការកសាងជញ្ជាំងនៅក្នុងទឹកដីកាន់ដោយប៉ាឡេស្ទីន,* ដីកាសម្រេចនៅថ្ងៃទី៣០ មិថុនា ២០០៤ (២០០៤) ICJ Rep 3 ។

[45] *រដ្ឋអាជ្ញា ទល់នឹង Sesay,* សេចក្តីសម្រេចលើញត្តិស្នើសុំរបស់មេធាវីក្នុងការធ្វើបណ្តឹងជំទាស់ចំពោះចៅក្រម Robertson នៃអង្គជំនុំជម្រះសាលាឧទ្ធរណ៍, សំណុំរឿងលេខ SCSL-2004-15-AR15, ចុះថ្ងៃទី១៣ មីនា ២០០៤ ។

១៦. ក្រមនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេសជាច្រើន មានចែងអំពីការធ្វើបណ្តឹងជំទាស់ចំពោះអ្នកជំនួយការច្បាប់[46]។ ចំពោះតុលាការនេះ ដែលពាក្យសុំត្រូវបានដាក់ជូនដោយជនត្រូវចោទតែម្នាក់នេះគត់ បានសំរេចថាកិច្ចស៊ើបសួររបស់ខ្លួនអាចប្រៀបធៀបបានទៅនឹងកិច្ចស៊ើបសួររបស់នគរបាលយុត្តិធម៌ ដែលមុខងាររបស់ពួកគេត្រូវបានគ្រប់គ្រងដោយមន្ត្រីតុលាការដែលពាក់ព័ន្ធ[47] ។ វាបានបន្ថែមថា វិធាននានាដែលធានាពីឯករាជ្យភាព និងភាពមិនលំអៀង "អនុវត្តចំពោះតែចៅក្រម និងមិនអនុវត្តចំពោះអ្នកស៊ើបអង្កេតទេ"[48]។ សេចក្តីសម្រេចនេះមិនត្រូវបានជនត្រូវចោទរូបនេះប្តឹងឧទ្ធរណ៍ទេ ដូច្នេះវាហួសពេលប្តឹងឧទ្ធរណ៍ដែលកំណត់ក្នុងច្បាប់ ។

១៧. ខណៈមានការពិចារណាទៅលើច្បាប់រដ្ឋប្បវេណី ដែលជំរុញឲ្យមានការគិតគូរអំពីយុត្តាធិការព្រហ្មទណ្ឌទាក់ទិននឹងការស៊ើបអង្កេត (ដែលប្រហាក់ប្រហែលនឹង អ.វ.ត.ក) តុលាការសិទ្ធិមនុស្សសហគមអឺរ៉ុប បានគូសបញ្ជាក់ថា មាត្រា៦ នៃ ECHR (ដែលធានាចំពោះសិទ្ធិនៃការជំនុំជម្រះក្តីដោយយុត្តធម៌ និងឯករាជ្យ) នឹងអនុវត្តជាបឋមចំពោះ *តុលាការ* នេះដែលត្រូវបានកោះហៅឲ្យមកធ្វើការកំណត់អំពីពិរុទ្ធភាពរបស់ចុងចោទណាម្នាក់[49]។ នៅលើបន្ទាត់ស្រដៀងនេះដែរ *សាលាវិនិច្ឆ័យ* នៃប្រទេសប៊ែលស៊ិក បានធ្វើការគូសបញ្ជាក់ពីភាពខុសគ្នារវាងចៅក្រមស៊ើបអង្កេត និងចៅក្រមជំនុំជម្រះនៅក្នុងការអនុវត្តន៍គោលការណ៍ឯករាជ្យភាព និងភាពមិនលំអៀង ។ សាលាវិនិច្ឆ័យនេះបានសំរេចថា ជាគោលការណ៍ មាត្រា៦ នៃ ECHR មិនមានកង្វល់អំពីការប្រើប្រាស់នូវសិទ្ធិរបស់ចុងចោទនៅចំពោះមុខយុត្តាធិការស៊ើបអង្កេតនោះទេ[50]។

## ៤. សេចក្តីសំអាង

[46] *ស្ថានភាពនៅក្នុងសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ ករណី ព្រះរាជអាជ្ញា ទល់នឹង Thomas Lubanga Dyilo,* ឧបសម្ព័ន្ធនានាដែលភ្ជាប់ទៅនឹងពាក្យសុំរបស់រដ្ឋអាជ្ញាឲ្យបំបែកទីប្រឹក្សាច្បាប់ជាន់ខ្ពស់នៃអង្គបុរេជំនុំជម្រះពីការផ្តល់ជំនួយផ្នែកច្បាប់ ទាក់ទិននឹងករណីនោះ, អង្គបុរេជំនុំជម្រះទី I នៃ ICC, សំណុំរឿងលេខ 01/04-01/06, ចុះថ្ងៃទី៣១ សីហា ២០០៦ ។

[47] សេចក្តីសម្រេចលើករណីលោក Heder, ទំព័រទី ១ ។

[48] សេចក្តីសម្រេចលើករណីលោក Heder, ទំព័រទី ២ ។

[49] *Imbrioscia ទល់នឹង ប្រទេសស្វីស,* សេចក្តីសម្រេច, ពាក្យសុំលេខ ១៣៩៧២/៨៨, ចុះថ្ងៃទី២៤ វិច្ឆិកា ១៩៩៣, កថាខណ្ឌទី ៣៦ ។

[50] ករណី (បែលស៊ិក), ចុះថ្ងៃទី១២ ធ្នូ ១៩៨២, Pas., 1983, I, 498-503 ។

### *សារណាមានការខ្វះចន្លោះទាំងទម្រង់ និង ទាំងខ្លឹមសារ*

១៨. សារណា គឺមិនច្បាស់លាស់ថាតើ (១) ជាគឺបណ្តឹងឧទ្ធរណ៍ ស្របតាមវិធាន ៧៤.៣ ដែលប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ឬ (២) ជាបណ្តឹងជំទាស់ចំពោះសហចៅក្រមមួយរូប ឬទាំងពីររូប[51] ស្របតាមវិធាន៣៤.៥ ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា បើសិនសារណានេះត្រូវបានគេគិតថា ជាបណ្តឹងឧទ្ធរណ៍ នោះវាត្រូវបានរារាំងដោយពេលវេលារួចហើយ មិនអាចទទួលយកបានទេ ហើយទោះក្នុងករណីណាក៏ដោយវាគ្មានអង្គសេចក្តីជាសារវ័ន្តឡើយ ។ ផ្ទុយមកវិញ បើសិនសារណានេះជាបណ្តឹងជំទាស់វិញ នោះវាមានការខ្វះចន្លោះនៅក្នុងទម្រង់របស់វា ខ្វះលក្ខណៈពិសេសជាក់ស្តែង ហើយជាថ្មីម្តងទៀតវាជាការយល់ខុសជាសារវ័ន្តផងដែរ ។

១៩. សារណានេះអាចជាបណ្តឹងឧទ្ធរណ៍ ឬជាបណ្តឹងជំទាស់ ។ វាមិនអាចទាំងពីរបានទេ តាមអ្វីដែលបណ្តឹងនេះបានទាមទារ[52] ។ លក្ខខ័ណ្ឌតម្រូវជាផ្លូវការ និងជាសារវ័ន្តនៃយន្តការទាំងពីរគឺវាមានលក្ខណៈខុសគ្នា និងជាន់គ្នាយ៉ាងខ្លាំង ។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាសូមស្នើឱ្យអង្គបុរេជំនុំជម្រះច្រានចោលសារណានេះដោយសារភាពស្រពិចស្រពិល និងការដាក់ឯកសារមិនបានត្រឹមត្រូវនៅចំពោះមុខអង្គជំនុំជម្រះ ។

### *សារណានេះ បើជាបណ្តឹងឧទ្ធរណ៍ មិនអាចទទួលយកបានទេ*

២០. សារណានេះ អះអាងថាជា *បណ្តឹងឧទ្ធរណ៍* "ស្របតាមវិធាន៣៤.៥"[53] ។ ច្បាស់ណាស់ថាបទប្បញ្ញត្តនោះមិនចែងឱ្យមានបណ្តឹងឧទ្ធរណ៍ណាមួយទេ ។ ហេតុដូច្នេះ សារណានេះ គឺមានលក្ខណៈស្រពិចស្រពិល និងខ្វះចន្លោះ ។

---

[51] សារណា, កថាខណ្ឌទី ១២-១៥ ។

[52] សារណា, កថាខណ្ឌទី ១៣-១៤ ។

[53] សារណា, ទំព័រទី ១ ។

២១. វិធាន៧៤.៣ បានរៀបរាប់គ្មានសល់នូវប្រភេទដីកាសម្រេចនានា ដែលជនត្រូវចោទអាចប្ដឹងឧទ្ធរណ៍បាន ទៅអង្គបុរេជំនុំជម្រះ ។ វិធាននេះគឺច្បាស់ណាស់ថា មិនបានគិតទៅដល់បណ្ដឹងឧទ្ធរណ៍ណាមួយ ដែលអាចនឹងប្រឆាំងទៅនឹងដីកាសម្រេចណាមួយដែលធ្វើការបដិសេធមិនព្រមផ្ដល់ព័ត៌មាន (ដូចជាសារណានេះជាដើម) ។ ហេតុដូច្នេះ លិខិតជាកម្មវត្ថុនៃការស្នើរដេញដោលនេះ មិនអាចប្ដឹងឧទ្ធរណ៍បានឡើយ ។

២២. ចរិតនៃវិធាន៧៤.៣ ដែលបានរៀបរាប់គ្មានសល់ ត្រូវបានលើកយកបង្ហាញដូចខាងក្រោម៖

i. ការអានជាធម្មតានៅត្រង់ផ្នែក ឃ នៃវិធានផ្ទៃក្នុងនេះបង្ហាញឲ្យឃើញថា យុត្តាធិការដ៏ចំបងរបស់អង្គបុរេជំនុំជម្រះ គឺដើម្បីកាត់សេចក្ដីទៅលើជម្លោះរវាងសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត[54] ។ តាមពិត កិច្ចព្រមព្រៀង និងច្បាប់អ.វ.ត.ក បានរំពឹងទុកចំពោះចំណុចនេះថាជា មុខងារតែមួយគត់របស់អង្គបុរេជំនុំជម្រះ[55] ។ វិធាន៧៣ មានចែងនូវ *យុត្តាធិការបន្ថែម* របស់អង្គបុរេជំនុំជម្រះ និងដាក់កំរិតយ៉ាងច្បាស់ចំពោះករណីទាំងឡាយណា ដូចបានរៀបរាប់នៅក្នុងវិធាននេះតែប៉ុណ្ណោះ ។

ii. ចំណងជើងនៃវិធាន៧៤ បានពន្យល់ខ្លួនឯងរួចហើយ៖ *មូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍* ។ វាបង្ហាញឲ្យឃើញថា មានតែដីកាណាដែលបានរៀបរាប់នៅក្នុងវិធាននេះតែប៉ុណ្ណោះ ដែលអាចប្ដឹងឧទ្ធរណ៍បាន នៅចំពោះមុខអង្គបុរេជំនុំជម្រះ ។ ហេតុដូចនេះ ខណៈដែលវិធាននេះ អនុញ្ញាតឲ្យសហព្រះរាជអាជ្ញាអាចប្ដឹងឧទ្ធរណ៍បានចំពោះដីកា *ទាំងអស់* របស់សហចៅក្រមស៊ើបអង្កេត វាបានដាក់កំរិតចំពោះសិទ្ធិក្នុងការប្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទណាម្នាក់ ប្រឆាំងនឹងដីកាទាំងឡាយណាដែលបានរៀបរាប់នៅក្នុងវិធាន៧៤.៣ ។

---

[54] វិធានផ្ទៃក្នុង, វិធាន ៧១-៧២ ។

[55] កិច្ចព្រមព្រៀង, មាត្រា ៧ ។ ច្បាប់ អ.វ.ត.ក, មាត្រា ២០(ថ្មី), មាត្រា ២៣(ថ្មី) ។

iii. វិធាននេះ មិនបានផ្តល់នូវយុត្តាធិការដែលនៅសេសសល់ណាមួយ ទៅឲ្យអង្គបុរេជំនុំជម្រះឡើយ ហើយវាក៏មិនបានផ្តល់នូវអំណាចចម្រុះណាមួយទៅឲ្យអង្គបុរេជំនុំជម្រះក៏ទេដែរ(ដូចជាអំណាចចម្រុះនៃតុលាការកំពូលជាតិជាដើម) ដើម្បីស្តាប់សវនាការនៃបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងសេចក្តីសម្រេចណាមួយ របស់សហចៅក្រមស៊ើបអង្កេតដែលមានការពេញចិត្តដោយភាគីណាមួយនោះ ។

២៣. មាត្រា២៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ក៏មានចែងផងដែរអំពីសិទ្ធិដែលបានដាក់កំរិតដែលសឹងតែស្រដៀងគ្នានឹងវិធាននេះដែរ ដើម្បីប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចណាមួយរបស់ចៅក្រមស៊ើបអង្កេត ។ មាត្រានេះមិនបានរំពឹងទុកអំពីបណ្តឹងឧទ្ធរណ៍ណាមួយដែលនឹងប្តឹងជំទាស់លើដីកាណាមួយដែលបដិសេធលើពាក្យសុំព័ត៌មានណាមួយ ទាក់ទិននឹងអ្នកស៊ើបសង្កេតណាម្នាក់ឡើយ ។

២៤. ហេតុដូចនេះ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងលិខិតសួរដេញដោល គឺច្បាស់ណាស់ថា វាហួសពីវិសាលភាពនៃវិធាន៧៤.៣ ហេតុនេះមិនអាចទទួលយកបានឡើយ ។

*សារណានេះ បើជាបណ្តឹងឧទ្ធរណ៍ ត្រូវបានរារាំងដោយពេលវេលា*

២៥. សេចក្តីសន្និដ្ឋាននេះត្រូវបានរារាំងដោយពេលវេលា ដោយសារជនត្រូវចោទបានដាក់សេចក្តីជូនដំណឹងពីបណ្តឹងឧទ្ធរណ៍របស់គាត់កាលពីថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៨ រួចហើយ ។ រយៈពេលកំណត់ចំនួន១០ថ្ងៃ សំរាប់ការដាក់បណ្តឹងនេះក៏ផុតកំណត់ហើយដែរនៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៨ ។ សារណាមិនបានផ្តល់នូវមូលហេតុពីការយឺតយ៉ាវនេះទេ ។ សារណានេះមិនមានទាំងសំណើណាមួយ ដែលផ្តល់នូវបុព្វហេតុល្អតិចតួចសំរាប់ការអនុគ្រោះក៏គ្មានផង ។ វាគ្រាន់តែបាននិយាយថា "មេធាវីការពារក្តីបានជូនដំណឹងផ្ទាល់មាត់ដល់ក្រឡាបញ្ជីនៃ ការិយាល័យ

សហចៅក្រមស៊ើបអង្កេត នៅថ្ងៃ ទី៥ ខែមិថុនា ឆ្នាំ២០០៨ [....] ពីគោលបំណងនៃការប្ដឹងឧទ្ធរណ៍របស់ខ្លួនតែប៉ុណ្ណោះ[56] ។

២៦. វិធាន៧៥.១ តម្រូវឲ្យអ្នកប្ដឹងឧទ្ធរណ៍ដាក់សេចក្ដីជូនដំណឹងពីបណ្ដឹងឧទ្ធរណ៍ ក្នុងរយៈពេល ១០ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសេចក្ដីជូនដំណឹងពីសេចក្ដីសំរេចស្នួរដេញដោល ។ ចំពោះករណីនេះ សហចៅក្រមស៊ើបអង្កេតបានចេញលិខិតស្នួរដេញដោលនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ ២០០៨ ហើយមន្ត្រីទទួលបន្ទុកសំណុំរឿងបានធ្វើទំនាក់ទំនងអំពីលិខិតនេះជាមួយមេធាវីរបស់ជនត្រូវចោទនៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៨[57] ។ ដូចនេះ សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ត្រូវបានកំណត់ត្រឹមថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៨ ។ សេចក្ដីណែនាំអនុវត្តដែលពាក់ព័ន្ធតម្រូវថាបុគ្គលណាម្នាក់ដាក់ឯកសារនៅក្រៅពេលវេលាកំណត់នេះ *ត្រូវ* បង្ហាញមូលហេតុអំពីការពន្យារពេលនៅលើសេចក្ដីណែនាំដាក់ឯកសារ ។ សេចក្ដីណែនាំអនុវត្តអនុញ្ញាតចំពោះ *តែ* ចៅក្រម ឬអង្គបុរេជំនុំជម្រះ *ប៉ុណ្ណោះ* ដើម្បីអភ័យទោសដល់ការដាក់សារណាដែលយឺតយ៉ាវនេះ[58] ។

២៧. វិធានក៏បានចែងទុកជាមុនផងដែរ អំពីសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីបណ្ដឹងឧទ្ធរណ៍ ហើយគឺមិនមែនជាសេចក្ដីជូនដំណឹងដោយផ្ទាល់មាត់នោះទេ។ នេះគឺជាការច្បាស់លាស់ណាស់គឺគេប្រើពាក្យ “ដាក់” (file) នៅក្នុងវិធាន៧៥.១ ។ ជាក់ស្ដែង សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ដោយផ្ទាល់មាត់នោះគឺមិនអាច *ដាក់* បានទេ ហើយហេតុដូចនេះគឺវាមិនមានសុពលភាពទេ។ នៅក្នុងសេចក្ដីណែនាំអនុវត្តក៏តម្រូវឲ្យដាក់ឯកសារណាដែលជាក្រដាសស្នាម(ជាលាយលក្ខណ៍អក្សរ)តែប៉ុណ្ណោះ (in hard copy only)[59] ។ ហេតុដូចនេះ

---

[56] សារណា, ទំព័រទី ១ ។

[57] លិខិតស្នួរដេញដោលបានបញ្ជូនទៅឲ្យគូភាគីនានា ដោយមន្ត្រីទទួលបន្ទុកសំណុំរឿង នៅវេលាម៉ោង ១៦:២២ នៅថ្ងៃទី២៧ ឧសភា ២០០៨ ។

[58] សេចក្ដីណែនាំអនុវត្ត, មាត្រា ៩ ។

[59] សេចក្ដីណែនាំអនុវត្ត, មាត្រា ៣.១ ។ (សេចក្ដីសង្កត់ន័យបន្ថែមជា *អក្សរទ្រេត*) ។

សេចក្តីជូនដំណឹងរបស់ជនត្រូវចោទដែលធ្វើឡើងដោយផ្ទាល់មាត់ទៅក្រឡាបញ្ជីកាលពីថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៨ នោះ គឺមិនមានសុពលភាពទេ។

***ការដាក់សារណាដាក់ជូន ក្នុងនាមជាអ្នកដាក់ពាក្យសុំជំទាស់ចិត្តនោះ***
***គឺមានការខ្វះខាតទាំងទម្រង់ និងខ្លឹមសារ***

២៨. ពាក្យសុំជំទាស់ចិត្តសហចៅក្រមស៊ើបអង្កេតណាម្នាក់ ត្រូវតែបំពេញឲ្យបានគ្រប់គ្រាន់នូវ*គ្រប់រាល់*សេចក្តីតម្រូវដូចមានតទៅនេះ។ ក្នុងពាក្យសុំនោះត្រូវ៖

i. បញ្ជាក់ពីអត្តសញ្ញាណនៃករណីរឿងណាមួយដែលនៅក្នុងនោះចៅក្រមណាម្នាក់ដែលមានផលប្រយោជន៍ផ្ទាល់ខ្លួន ឬផលប្រយោជន៍ខាងហិរញ្ញវត្ថុផ្ទាល់ខ្លួនក្នុងនោះ ឬដែលក្នុងនោះចៅក្រមបាន ឬធ្លាប់បានចូលរួមសមាគមតាមបែបណាមួយដែលជាគោលដៅអាចនឹងធ្វើឲ្យមានការប៉ះពាល់ទៅដល់ភាពមិនលំអៀងរបស់គាត់ ឬជាគោលដៅ ធ្វើឲ្យគេមើលឃើញថាមានភាពលំអៀង[60]។

ii. ចង្អុលបង្ហាញអំពីមូលហេតុផ្សេងៗដើម្បីសុំជំទាស់ចិត្ត និងអំពីភស្តុតាងនានាសម្រាប់គាំទ្រ[61]។

ii. ដាក់ជូនភ្លាមបន្ទាប់ពីអ្នកដាក់ពាក្យសុំបានចាប់ផ្តើមដឹងអំពីមូលហេតុដើម្បីសុំជំទាស់ចិត្ត[62]។

២៩. សារដាក់ជូន មិនបានបំពេញតាមសេចក្តីតម្រូវណាមួយក្នុងចំណោមសេចក្តីតម្រូវទាំងនោះទេ។ ជាពិសេស៖

---

[60] វិធានផ្ទៃក្នុង, វិធាន ៣៤.២ ។

[61] វិធានផ្ទៃក្នុង, វិធាន ៣៤.៣ ។

[62] វិធានផ្ទៃក្នុង, វិធាន ៣៤.៣ ។

i. សារណាដាក់ជូននោះតែម្តង ពេលដែលដាក់ទៅនោះ ជាក់ស្តែងគឺវាមិនមែនជាសំណើដើម្បីសុំដឹតចិត្តនោះទេ[63]។

ii. ក្នុងសារណាដាក់ជូននោះ មិនបានបញ្ជាក់អត្តសញ្ញាណថាតើស្នើសុំដឹតចិត្តសហចៅក្រមស៊ើបអង្កេតណាមួយ។ ជាការច្បាស់ណាស់ថាចៅក្រមនេះគឺមានពីររូប។

iii. សារណាដាក់ជូននោះមិនបានបញ្ជាក់ច្បាស់អំពីករណីរឿងណាមួយដែលចៅក្រមមួយរូប ឬទាំងពីររូបមានផលប្រយោជន៍ផ្ទាល់ខ្លួន ឬផលប្រយោជន៍ខាងហិរញ្ញវត្ថុក្នុងនោះ។ ជាក់ស្តែង ក្នុងសារណានោះគ្មានបានលើកសំអាងទេ។

iv. ក្នុងសារណាដាក់ជូននោះ មិនបានបញ្ជាក់ពីអត្តសញ្ញាណនៃករណីរឿងក្តីណាមួយដែលក្នុងនោះចៅក្រមមួយរូប ឬទាំងពីររូបបាន ឬធ្លាប់បានចូលរួមសមាគមតាមបែបណាមួយនៅក្នុងនោះដែលជាគោលដៅគឺវាអាចនឹងប៉ះពាល់ទៅដល់ភាពមិនលំអៀងរបស់ពួកគាត់ ឬជាគោលដៅ ធ្វើឲ្យគេមើលឃើញថាមានភាពលំអៀង។

v. ក្នុងសារណាដាក់ជូននោះមិនបានចង្អុលបង្ហាញឲ្យឃើញពីមូលហេតុដើម្បីសុំដឹតចិត្តនោះទេ ។ គឺគ្រាន់តែសុំឲ្យផ្តល់ពត៌មានស្តីពីអ្នកស៊ើបអង្កេតមួយរូបនៃការិយាល័យសហចៅក្រមស៊ើបអង្កេតតែប៉ុណ្ណោះ។ គឺក្នុងសារណានោះមិនបានលើកឡើងអំពីថាតើគ្រាន់តែជាអ្នកស៊ើបអង្កេតមួយរូបតែប៉ុណ្ណោះអាចនឹងមានឥទ្ធិពលបែបដូចម្តេចខ្លះទៅលើសេចក្តីសម្រេចមួយ(ឬច្រើន)របស់សហចៅក្រមស៊ើបអង្កេតទាំងពីររូបនោះទេ នៅពេលដែលចំនួនអ្នកស៊ើបអង្កេត និងមន្ត្រីផ្នែកច្បាប់ដែលធ្វើការនៅខាងផ្នែកជាតិ និងខាងផ្នែកអន្តរជាតិនៅក្នុងការិយាល័យនោះ មានច្រើនលើសពីដប់នាក់ទៅទៀតឯណោះ។

---

[63] សារណា, កថាខណ្ឌទី ១៣ ។

00197206



vi. ជាការច្បាស់ណាស់ នៅក្នុងសារណាដាក់ជូននោះ មិនបានបញ្ជាក់ច្បាស់អំពីថាតើនៅពេលណាដែលជនត្រូវចោទបានចាប់ផ្តើមដឹងថា មានមូលហេតុដើម្បីសុំដឹតចិត្តនោះទេ បើសិនជាមាន តើគេមានបានដាក់ពាក្យសុំនោះភ្លាមៗបន្ទាប់ពីបានចាប់ផ្តើមដឹងនោះដែរ ឬទេ?

vii. សារណាដាក់ជូននោះ នៅពេលត្រូវបានគេទទួលយក គឺមិនឃើញមានផ្តល់នូវភស្តុតាងណាមួយដើម្បីគាំទ្រទេ[64]។

៣០. អាស្រ័យហេតុនេះ សារណាដែលដាក់ជូននេះ គឺមានលក្ខណៈមិនគ្រប់គ្រាន់ និងមិនអាចទទួលយកបានទេ នៅក្នុងការរៀបចំទាំងពីរផ្នែកនៃសារណានេះ ដែលគួរតែត្រូវបដិសេធចោលតាំងពីដើមដំបូងទី (*in limine*) ។

### *ក្នុងវិធានគឺមិនអនុញ្ញាតឲ្យស្នើសុំប្តឹងដោយគ្មានមូលហេតុគាំទ្រនោះទេ*

៣១. នៅក្នុងសំណុំរឿងដែលក្នុងនោះជនត្រូវចោទរូបនេះកំពុងត្រូវធ្វើការស៊ើបសួរ តុលាការនេះបានសម្រេចថា ក្នុងវិធាន និងនៅក្នុងទម្លាប់អនុវត្តរបស់កម្ពុជាហើយនិងរបស់អន្តរជាតិ គឺសុទ្ធតែមិនបានចែងអំពីការស្នើសុំផ្តល់ព័ត៌មានចម្រុះទាក់ទងអំពីចៅក្រមនានា និងមន្ត្រីស៊ើបអង្កេតទាំងឡាយរបស់ពួកគាត់ទេ។ ដោយមិនទាន់បានធ្វើការប្តឹងឧទ្ធរណ៍ជំទាស់នោះ សេចក្តីសម្រេចទាំងនោះក៏បបានឈានចូលជាស្ថាពរ។ ទោះបីជាធ្វើការសន្មតថា សំណើមួយនេះត្រូវបានគេអនុញ្ញាតឲ្យដើម្បីផលប្រយោជន៍នៃការលើកសំអាងនោះក្តី ក៏ពាក្យសុំរបស់ជនត្រូវចោទនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតមានលក្ខណៈជាសំណើដែលមិនសំដៅទៅលើអ្វីមួយឲ្យបានច្បាស់និងទូលំទូលាយពេក ដែលមិនចង្អុលឲ្យចំទៅលើភស្តុតាងណាមួយដែលថាវាអាចនឹងបណ្តាលឲ្យមានការជ្រៀតជ្រែក ឬដែលធ្វើឲ្យគេមើលឃើញថាមានភាពលំអៀងពី

---

[64] សារណា, កថាខណ្ឌទី ១៣ ។

សំណាក់សហចៅក្រមស៊ើបអង្កេតឬ ពីអ្នកអង្កេតណាមួយនោះឡើយ។ ឧទាហរណ៍ដូច ជាពាក្យសុំឲ្យផ្តល់ព័ត៌មានផ្សេងៗនោះគឺមានព័ត៌មានអំពីដូចខាងក្រោមនេះ ៖

i. អំពីគ្រប់រាល់ក្រដាសស្នាម ជំពូកនានានៅក្នុងសៀវភៅ និង "លិខិតផ្ញើជូនអ្នកនិពន្ធជាដើម...។ល។ ស្តីអំពីអ្វីដែលទាក់ទងទៅនឹងស្នាដៃរបស់ អ.វ.ត.ក"។

ii. ព័ត៌មានផ្សេងៗស្តីពីគ្រប់រាល់អង្គសន្និសីទ សិក្ខាសាលា សវនាការ ការធ្វើបទកថា សិក្ខាសាលារៀនសូត្រ និងរាល់ការប្រជុំទាំងអស់ទាក់ទងទៅនឹង អ.វ.ត.ក ដែលក្នុងនោះអ្នកស៊ើបអង្កេតបានចូលរួម។

iii. អនុស្សារណៈផ្ទៃក្នុងនានារបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលបានរៀបរៀងដោយអ្នកស៊ើបអង្កេតរូបនោះ។

iv. សេចក្តីរៀបរាប់អំពីការចូលរួមរបស់អ្នកស៊ើបអង្កេតរូបនោះ នៅក្នុងការធ្វើសេចក្តីព្រាងនៃដីកាសម្រេចឃុំខ្លួនជនត្រូវចោទរូបនេះ។

v. សេចក្តីរៀបរាប់អំពីតើការិយាល័យសហចៅក្រមស៊ើបអង្កេតបានដឹងអំពីសំណោរអ្វីខ្លះរបស់មន្ត្រីស៊ើបអង្កេតរូបនេះនៅមុនពេលចូលមកបំរើការងារនេះ[65]។

៣២. ទោះបីមានការលាយលក្សអក្សរជាសំណើសុំបង្ហាញជូន និងដែលមិនមែនជាពាក្យសុំដ៏តចិត្តមួយដ៏មានសារៈសំខាន់ក្តី ក៏ក្នុងពាក្យសុំនោះខកខានមិនបានលើកឡើងយោងទៅលើឧទាហរណ៍ ជាក់លាក់ណាមួយអំពីស្នាដៃរបស់អ្នកស៊ើបអង្កេតដែលបានធ្វើឲ្យគេមើលឃើញថាមានភាពលំអៀង ដែលធ្វើយុត្តិកម្មចំពោះសំណើសុំឲ្យបង្ហាញនោះដែរ ។ បើសិនជាជនត្រូវចោទបានដាក់ពាក្យសុំដោយគ្រាន់តែសង្ស័យថា ព័ត៌មានដែលស្នើសុំនោះអាចនឹងបញ្ចេញ

[65] ពាក្យសុំ, ទំព័រទី ៤-៥ ។

ឲ្យដឹងអំពីភស្តុតាងមួយចំនួនដែលខ្លួនអាចនឹងពឹងផ្អែកបានដើម្បីសុំដឹតចិត្តនោះ នោះពាក្យសុំដូចដែលបានដាក់មក គឺជាបេសកកម្មចេញទៅស្ទូចត្រីមួយយ៉ាងច្បាស់ណាស់ ដែលមានលក្ខណ:គ្រប់គ្រាន់ដែលសមតែត្រូវបានបដិសេធចោល ។ ទោះជាយ៉ាងណាក្តី ព័ត៌មានដែលបានស្នើសុំផ្តល់ដែលស្ថិតនៅក្នុងប្រភេទទី(i) និងទី(ii) រួមបញ្ចូលនូវឯកសារដែលមានស្រាប់រួចហើយដែលជាទ្រព្យសម្បត្តិសាធារណ:(public domain) និង/ឬ ដែលទំនងជាមិនចាំបាច់ជាកម្មសិទ្ធិរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតនោះទេ ។ រីឯប្រភេទទី(iii) និងទី(iv) វិញ ពត៌មានអាចជាប់ទាក់ទងទៅនឹងផលិតផលនៃការងារផ្ទៃក្នុងរបស់ការិយាល័យនេះ ដែលដោយសារតែមូលហេតុនៃការសម្ងាត់នោះ គឺមិនអាចយល់ព្រមផ្តល់ឲ្យទៅតាមការស្នើសុំឲ្យបញ្ចេញឲ្យដឹងនោះបានទេ ។

### *វិធានមិនមានចែងអំពីការសុំដឹតចិត្តមន្ត្រីស៊ើបអង្កេតនោះទេ*

៣៣. ដូចគ្នានឹងតុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀតដែរ ចៅក្រមទាំងឡាយនៃតុលាការនេះ គឺបានទទួលនូវឋាន: បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិពិសេសទាំងនេះ[66]។ សេចក្តីតម្រូវផ្សេងៗអំពីឯករាជ្យភាព និងភាពមិនលំអៀង ភាពពិតប្រាកដ និងភាពដែលឃើញជាក់ស្តែង គឺសំខាន់បំផុតសម្រាប់ការបំពេញភារកិច្ចរបស់ខ្លួន[67] លើសពីនេះចៅក្រមទាំងឡាយបានអនុម័តនូវក្រមសីលធម៌សម្រាប់តុលាការដោយស្ម័គ្រចិត្តមួយ (a voluntary Code of Judicial Ethics) ដើម្បីពង្រឹងនូវសញ្ញាណអំពីភាពឯករាជ្យ និងមិនលំអៀងរបស់ខ្លួន[68]។ ក្នុងការរក្សានូវឋាន:ពិសេស និងសេចក្តីតម្រូវអំពីឯករាជ្យភាពនិងភាពមិនលំអៀងរបស់ខ្លួននេះ វិធានទាំងនេះបានដាក់ចេញនូវនីតិវិធីជាក់លាក់និងដែលអាចឲ្យតុលាការធ្វើការកំណត់បានអំពីការសុំដឹតចិត្តចៅក្រមនានារបស់តុលាការនេះ[69]។

---

[66] វិធានផ្ទៃក្នុង, វិធាន ៦.២-៦.៣ ។

[67] វិធានផ្ទៃក្នុង, វិធាន ៦.១ ។

[68] អាចរកបានតាមគេហទំព័រ http://www.eccc.gov.kh/english/cabine/fileUpload/31/Code_of_udicial_ethics_31-01-08-ENG.pdf.

[69] វិធានផ្ទៃក្នុង, វិធាន ៣៤ ។

៣៤. ក៏ប៉ុន្តែអ្នកស៊ើបអង្កេតទាំងឡាយរបស់តុលាការនេះ គឺជានិយោជិតរបស់ អ.វ.ត.ក ឬរបស់អង្គការសហប្រជាជាតិ ដែលហេតុដូចនេះត្រូវបានគ្រប់គ្រងដោយបទបញ្ជាផ្សេងៗរបស់ស្ថាប័នទាំងនោះ[70]។ ថ្វីបើពួកគេត្រូវជាប់កាតព្វកិច្ចក្នុងការបំពេញភារកិច្ចរបស់ខ្លួនផងដែរ ដោយមិនមានការជ្រៀតជ្រែកពីខាងក្រៅនោះក្តី[71] ក៏ពួកគេត្រូវស្ថិតនៅក្រោមការត្រួតត្រាមើលខាងវិន័យ(ដែលរួមមានទាំងសិទ្ធិក្នុងការដកហូតចេញពីដំណែង)ពីខាងអាជ្ញាធរជាតិ និងអង្គការសហប្រជាជាតិដែលមានសមត្ថកិច្ចផង[72]។ ដោយហេតុនេះហើយ ដំណើរការនីតិវិធីដើម្បីសុំដឹតចិត្តអ្នកស៊ើបអង្កេតដែលមានលក្ខណៈជារដ្ឋបាល និងដែលមិនត្រូវដាក់ឲ្យស្ថិតនៅក្រោមការកំណត់សម្រេចរបស់តុលាការនោះទេ លុះត្រាតែចាំបាច់ត្រូវអនុវត្តបញ្ញត្តិស្តីពីការដាក់ទណ្ឌកម្មនៅក្នុងវិធាន៣៥ (ចំពោះការជ្រៀតជ្រែកនៅក្នុងការគ្រប់គ្រងយុត្តិធម៌) ។

៣៥. ក្នុងពេលកន្លងមក អង្គបុរេជំនុំជម្រះ ធ្លាប់បានធ្វើការបដិសេធពាក្យសុំមួយរបស់ជនត្រូវចោទ នួន ជា ដែលបានស្នើសុំឲ្យផ្តល់ព័ត៌មានអំពីប្រវត្តិផ្ទាល់ខ្លួននិងអំពីវិជ្ជាជីវៈរបស់ចៅក្រមនានា[73] ។ អង្គបុរេបានសម្រេចថា ទាំងនៅក្នុងវិធានក្តី ឬទាំងនៅក្នុងទម្លាប់អនុវត្តរបស់កម្ពុជា ឬរបស់អន្តរជាតិក្តី គឺទាំងអស់សុទ្ធតែគ្មានចែងអំពីការផ្តល់ពត៌មានបែបដូចនេះទេ[74]។

៣៦. នៅក្នុងសារណាដាក់ជូន ការពឹងផ្អែកទៅលើសេចក្តីសម្រេចរបស់តុលាការ ICC នៅក្នុងករណីរឿងក្តីរបស់ *Lubanga* និងទៅលើសេចក្តីសម្រេចរបស់តុលាការសហព័ន្ធមួយរបស់អាមេរិកក្នុងករណីរឿក្តីរបស់ *Hall* គឺជាការភាន់ច្រឡំហើយ[75]។ ក្នុងករណីទាំងនោះ

---

[70] វិធានផ្ទៃក្នុង, វិធាន ៦ ។

[71] វិធានផ្ទៃក្នុង, វិធាន ៦.១ ។

[72] វិធានផ្ទៃក្នុង, វិធាន ៦.៤។

[73] *ករណីរឿងក្តីរបស់ នួន ជា* ការបង្ហាញជូននូវលិខិតតែងតាំងមុខតំណែង, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស , លេខERN 00156722, C11/13 ចុះថ្ងៃទី១៩ ធ្នូ ២០០៧។

[74] *ករណីរបស់ នួន ជា,* សំណើសុំផ្តល់ប្រវត្តិរូបសង្ខេបរបស់ចៅក្រមទាំងឡាយនៃ អ.ប.ជ, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច (អ.ប.ជ ០១) លេខERN 00157561, C11/16 ចុះថ្ងៃទី០៩ មករា ២០០៨ ។

[75] សារណា, លេខយោងជើងទំព័រទី ៨, ១៣ ។

គឺជាប់ទាក់ទងទៅនឹងមន្ត្រីផ្លូវការណ៍/និយោជិត របស់ការិយាល័យនានារបស់តុលាការដែលមាននិយោជក-និយោជិតមានទំនាក់ទំនងគ្នាជាមួយនឹងភាគីមួយដែលនៅចំពោះមុខចៅក្រមដែលខ្លួនកំពុងតែជួយ ឬផ្តល់ការប្រឹក្សាយោបល់។ ស្ថានភាពរបស់អ្នកស៊ើបអង្កេតគឺមានលក្ខណៈផ្សេងដែលខុសពីគ្នាទាំងស្រុងតែម្តង។ ក្នុងចំណោមអ្វីៗផ្សេងទៀតជាច្រើននោះ គឺក្នុងករណីចំពោះមុខនេះ ៖

i. មន្ត្រីស៊ើបអង្កេតនេះ មិនដែលធ្លាប់មានការទំនាក់ទំនងណាមួយដោយផ្ទាល់ខ្លួន ឬខាងវិជ្ជាជីវៈជាមួយនឹងភាគីណាមួយដែលនៅចំពោះមុខតុលាការនេះទាល់តែសោះ។ ដែលទោះបីជាយ៉ាងណាក្តី នៅក្នុងសារណាដាក់ជូនមិនបានចោទប្រកាន់ដូចនេះទេ។

ii. មិនមានការចោទប្រកាន់(ឬភស្តុតាង) អំពីមានភាពលំអៀងជាអត្តនោម័ត ឬក៏ជាសត្យានុម័តនោះទេ។

iii. អ្នកស៊ើបអង្កេតបំរើការងារឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលថ្វីត្បិតតែកំពុងស្ថិតនៅក្នុងភាពជាអព្យាក្រិត្យក្តី ក៏មិនបានកំណត់ អំពីភាពស្លូតត្រង់ ឬមួយក៏មានទោសរបស់ចុងចោទនោះដែរ។

iv. បញ្ជើរៀបរាប់ពីភារកិច្ចរបស់អ្នកស៊ើបអង្កេត គឺប្រហាក់ប្រហែលគ្នានឹងភារកិច្ចរបស់នគរបាលយុត្តិធម៌ដែរ ដែលធ្វើការងារក្រោមការត្រួតពិនិត្យរបស់សមត្ថកិច្ចដែលពាក់ព័ន្ធនៃតុលាការ។ អ្នកស៊ើបអង្កេត មិនមានសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចរបស់តុលាការនោះទេ ក៏ប៉ុន្តែធ្វើការងារយ៉ាងម៉ត់ចត់តាមរយៈដីកាចាត់ស៊ើបសួរជំនួស។

### *ការសំដែងមតិយល់ឃើញផ្សេងៗស្តីពីបញ្ហាច្បាប់មិនមែនជាការលំអៀងនោះទេ*

៣៧. ការសំដែងមតិរបស់អ្នកស៊ើបអង្កេតណាម្នាក់ (ដែលជាមេធាវីដែលមានគុណសម្បត្តិដែរនោះ) លើបញ្ហាច្បាប់ទាក់ទងនឹង*ខ្មែរក្រហម* និងការបង្កើត អ.វ.ត.ក (ទោះបីតាំងពីពេលមិនទាន់

ត្រូវបានបង្កើតឡើងក្តី) តាមអង្គហេតុនោះផ្ទាល់ (*ipso facto*) គឺមិនត្រូវសុំដកចេញមិនឱ្យមន្ត្រីរូបនោះធ្វើការនៅក្នុងការិយាល័យមួយរបស់តុលាការនោះទេ ។ មេធាវីទាំងឡាយ ក៏ដូចគ្នានឹងចៅក្រមនានាដែរ ជាញឹកញយតែងតែត្រូវបានគេអញ្ជើញឱ្យទៅនិយាយជាសាធារណៈអំពីបញ្ហាផ្សេងៗដែលមានការពាក់ព័ន្ធនៅក្នុងពេលបច្ចុប្បន្ន ។ តាមពិត ការធ្វើសេចក្តីអត្ថាធិប្បាយផ្សេងៗរបស់ពួកគាត់ជាសាធារណៈ ឬក្នុងកំរិតជាបណ្ឌិតជាន់ខ្ពស់ គឺជាគុណសម្បត្តិរបស់ពួកគាត់ដែលត្រូវគេជួលឱ្យមកបំរើការងារនៅការិយាល័យច្បាប់ឬ ការិយាល័យតុលាការនោះហើយ។ ការបញ្ចេញទស្សនៈរបស់មន្ត្រីស៊ើបអង្កេតដែលបានទទួលការហ្វឹកហ្វឺនតាមច្បាប់ ដែលមានលក្ខណៈជាទូទៅមិនគួរចាំបាច់ឈានទៅដល់ការធ្វើសេចក្តីសន្និដ្ឋានថា គាត់នឹងមានទំនោរអនុវត្តទៅតាមទស្សនៈទាំងនោះនៅពេលជួយដល់ការិយាល័យរបស់តុលាការនៅក្នុងករណីរឿងក្តីដោយឡែកណាមួយឡើយ។

## ៦. សេចក្តីសន្និដ្ឋាន

៣៨. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញា សូមស្នើដល់ អង្គបុរេជំនុំជម្រះ ឱ្យបដិសេធចោលនូវសារណាដាក់ជូនរបស់ អៀង សារី ដោយសារមិនអាចទទួលយកបាន ដោយសារហួសពេលវេលា ទម្រង់មានលក្ខណៈមិនគ្រប់គ្រាន់ ហើយក្នុងករណីណាក៏ គឺដោយគ្មានអង្គសេចក្តីទាល់តែសោះ ។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨

**សហព្រះរាជអាជ្ញា**

**លោកស្រី ជា លាង** **លោក** Robert PETIT